ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ ៦៧៦ "ច១" ក្រ១០
ចុះថ្ងៃទី ០៧.០៩.២០២២
-សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៨៦២
ចុះថ្ងៃទី ១៦.០៦.២០២២
-សំណុំរឿងស៊ើបសួរ
លេខ ២២៣៧
ចុះថ្ងៃទី ១៧.០៦.២០២២
-សំណុំរឿងជំនុំជម្រះ
លេខ ៣៣៥១
ចុះថ្ងៃទី ០៨.០៩.២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ និងនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ សាលសវនាការទី៣ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សា ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សា ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សា ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

## ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ២៨៦២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរយោធា ទីកន្លែងកំណើត ភូមិ[redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ[redacted] ផ្លូវបេតុង ភូមិ[redacted] [redacted] [redacted] រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន០២នាក់ ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោះ[redacted] "ស" ទោសពីមុនគ្មាន ជានីតិជន (ក្រៅឃុំ) ។

**-ដីកាបង្គាប់ឱ្យដោះលែងលេខ ៦៨៣៧ "វ" ដ.ឃ.ង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ (ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ PJ) ។**

ជាប់ចោទពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ៥៩EO ផ្លូវលេខ[redacted] [redacted] [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

មេធាវី [redacted] អគ្គលេខ ១៧០០ មានអាសយដ្ឋាន ផ្ទះលេខ១៥ ផ្លូវលេខ២៥៣ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

មេធាវី [redacted] សុក្រសំណាង អត្តលេខ ២៥៣០T មានការិយាល័យ ភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

មេធាវី [redacted] ឧត្តម អត្តលេខ ២៥០៣T មានអាសយដ្ឋាន ផ្ទះលេខ១២រាកឺ០ ផ្លូវលេខ៤៨២ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់អង្ករ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] បញ្ញា ហៅ [redacted] ហ៊ វ ភេទស្រី អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ៥៩ ផ្លូវលេខ១១៦ ភូមិ [redacted] រាជធានីភ្នំពេញ ។

លោកស្រីមេធាវី [redacted] សុវ៉ន អត្តលេខ ១៨១ ជាមេធាវីនៃក្រុមមេធាវីច្បាប់ និងពិគ្រោះយោបល់ មានការិយាល័យ ផ្ទះលេខ២១១០B ផ្លូវជាតិលេខ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ ។

-បានឃើញរបាយការណ៍សរុបលេខ ០២៦/២២ រ.ប.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ស្នងការដ្ឋានស្រាវជ្រាវ និងបង្ក្រាបបទល្មើសការិយាល័យប្រឆាំងការជួញដូរមនុស្ស ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២២៣៣ អ.យ.ង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣១៤៩ អ.យ.ង ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤១២៩ "វ" ដ.ជ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបង្គាប់ឱ្យដោះលែងលេខ ៦៨៣៧ "វ" ដ.ឃ.ជ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃមិនចាំ អំឡុងខែសីហា ឆ្នាំ២០២០ នៅចំណុចផ្ទះលេខ៥៩Eo ផ្លូវលេខ១១៦ ក្រុម៦ ភូមិដំណាក់ធំ២ មណ្ឌល៨ [redacted] រាជធានីភ្នំពេញ មានករណី **រំលោភសេពសន្ថវៈ** មួយបានកើតឡើង ប្រព្រឹត្តដោយឈ្មោះ [redacted] រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ ដោយមុនពេលកើតហេតុឈ្មោះ [redacted] រឿន បានមានទំនាក់ទំនងរួមរស់នៅជាអនីតិសង្វាសជាមួយឈ្មោះ [redacted] ខុន ភេទស្រី អាយុ ៤១ឆ្នាំ ។ ក្នុងអំឡុងពេលនៃទំនាក់ទំនងរួមរស់ជាអនីតិសង្វាសនោះ ឈ្មោះ [redacted] រឿន បានប្រព្រឹត្តអំពើ**រំលោភសេពសន្ថវៈ** បានសម្រេចលើជនរងគ្រោះឈ្មោះ [redacted] បញ្ញា ភេទស្រី កើតថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥ ។ ទើបថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ម្ដាយជនរងគ្រោះក៏បានទៅដាក់ពាក្យស្នើសុំកិច្ចអន្តរាគមន៍ចូលមក

ក្រសួងកិច្ចការនារី ។ រហូតដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ម៉ោងប្រហែល១៥ និង០០នាទី ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើការស្រាវជ្រាវឃាត់ឈ្មោះ [redacted]វឿន មកសាកសួរ នៅការិយាល័យប្រឆាំងការជួញដូរមនុស្ស រួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមក អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]វឿន បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០២០ ខ្លួនមានស្នេហាលួចលាក់ជាមួយឈ្មោះ [redacted]ខុន ក្រោយពេលដែលគាត់លែងលះប្តីគាត់ហើយ ។ នៅពេលដែលមានស្នេហាស៊ីជម្រៅនោះ ខ្លួន និងឈ្មោះ [redacted]ខុន បានជួបគ្នាតែពេលយប់នោះទេ ហើយបានរយៈពេលពី៣០ ទៅ៤០នាទី ប៉ុន្តែក្នុងអំឡុងពេលនោះខ្លួនរួមរស់នឹងគាត់បានតែ៣ដងតែប៉ុណ្ណោះ បន្ទាប់មកទើបយើងមានការអាក់អន់ចិត្តគ្នារហូតឈានដល់ការបែកគ្នា ។ នៅពេលដែលខ្លួនទៅជួបគាត់កន្លងមកនោះ គឺពុំដែលមានជួបកូនៗរបស់គាត់ឡើយ ព្រោះខ្លួនទៅលួចលាក់ប្រពន្ធត្រឹម៣០ ទៅ៤០នាទី នៅពេលដែលទៅម្តងៗ គឺឈ្មោះ [redacted]ខុន ជាអ្នកហៅខ្លួនរហូត ។ ខ្លួនសុំបដិសេធចោលទាំងស្រុង ចំពោះការការចោទប្រកាន់របស់តំណាងអយ្យការដែលចោទប្រកាន់ខ្លួនពីបទ រំលោភសេពសន្ថវៈ ទៅលើឈ្មោះ [redacted]បញ្ញា ។ ស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ និងសម្រេចឱ្យរួចផុតបទចោទ ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ខុន បានឆ្លើយថា៖ នៅចុងខែតុលា ឆ្នាំ២០២០ កូនស្រីរបស់ខ្លួនឈ្មោះ [redacted]បញ្ញា បានប្រាប់ខ្លួនថាឈ្មោះ [redacted]វឿន បានចាប់រំលោភគាត់ ទើបខ្លួនមានរឿងឈ្លោះប្រកែកគ្នា ហើយឈ្មោះ [redacted]វឿន បានប្រាប់ខ្លួនថា គាត់ចង់បានខ្លួន និងកូនធ្វើជាប្រពន្ធរបស់គាត់ទាំងពីរនាក់ បើខ្លួនហ៊ានបែកពីគាត់ គាត់នឹងបាញ់សម្លាប់ខ្លួនចោល ។ កូនស្រីរបស់ខ្លួនបានប្រាប់ខ្លួនថាឈ្មោះ [redacted]វឿន បានចាប់រំលោភគាត់បានសម្រេចចំនួន៧ដង មានពេលខ្លះទាំងដែលកំពុងមករដូវផងដែរ ។ ខ្លួនសុំសំណូមពរឱ្យតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ និងទាមទារសំណងជម្ងឺចិត្តចំនួន ១០០.០០០$ ។

-ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]បញ្ញា បានឆ្លើយថា៖ ឈ្មោះ [redacted]វឿន ចាប់រំលោភខ្លួនបានសម្រេចសរុបចំនួន៧ដង សុទ្ធតែនៅក្នុងផ្ទះទាំងអស់ ដែលខ្លួនពុំដែលយល់ព្រមឡើយ និងខ្លួនពុំដែលហ៊ានប្រាប់ម្តាយដោយសារតែឈ្មោះ [redacted]វឿន គំរាមបើហ៊ានប្រាប់គាត់នឹងសម្លាប់ចោលទាំងម្តាយកូន ។ នៅចុងខែតុលា ឆ្នាំ២០២២ បន្ទាប់ពីម្តាយរបស់ខ្លួនបានបែកគ្នាជាមួយគាត់ ទើបខ្លួនប្រាប់ម្តាយរបស់ខ្លួនអំពីរឿងរ៉ាវដែលឈ្មោះ [redacted]វឿន បានចាប់រំលោភខ្លួន ម្តាយរបស់ខ្លួនក៏បានទូរស័ព្ទសួរនាំ និងឈ្លោះប្រកែកគ្នា ហើយឈ្មោះ [redacted]វឿន បានគំរាមកំហែងដដែល ។ អស់រយៈពេល២ឆ្នាំ ដោយមានការឈឺចាប់បន្ទាប់ពីចាប់រំលោភពីឈ្មោះ [redacted]វឿន រួចមក បានបន្សល់ទុកជម្ងឺ ធ្លាក់ស ក្លិនមិនល្អ រមាស់ មានរដូវមិនទៀងទាត់ ធ្វើឱ្យអារម្មណ៍ដល់ខ្លួនជាខ្លាំង ទើបម្តាយខ្លួនដាច់ចិត្តដាក់ពាក្យបណ្តឹងតែម្តង ខ្លួនសុំសំណូមពរឱ្យតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ ។

-ឈ្មោះ [redacted] ធីណា (ត្រូវជាប្អូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវជាម្តាយមីងរបស់ជនរងគ្រោះ) ឆ្លើយថា៖ ខ្លួនឈ្មោះ [redacted] ធីណា មានទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះ[redacted] ផ្លូ[redacted]រាជធានីភ្នំពេញ ។ ខ្លួនបានដឹងរឿងក្មួយស្រីឈ្មោះ [redacted]បញ្ញា ដោយប្អូនអត្ត

ចរិត ប្រែជាក្រៀមក្រំពុំសូវនិយាយស្តី និងលេងសើចដូចកាលមុនៗ ទើបខ្លួនសួរក្មួយស្រី ហើយនាងក៏បានឆ្លើយប្រាប់ថាឈ្មោះ[redacted]រឿន បានចាប់រំលោភ និងបានគំរាមកំហែងថានឹងសម្លាប់ មិនឱ្យប្រាប់អ្នកណាឱ្យដឹងឡើយ ។ ដោយក្នុងហេតុការណ៍នេះខ្លួនពុំបានដឹង ពុំបានឃើញ និងពុំបានលឺផ្ទាល់ឡើយ គ្រាន់តែស្តាប់តាមការរៀបរាប់របស់ក្មួយស្រីតែប៉ុណ្ណោះ ។ ផ្ទះរបស់ខ្លួន និងផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅជិតគ្នា ខ្លួនពុំធ្លាប់បានស្គាល់ឈ្មោះ [redacted]រឿន ឡើយ គឺគ្រាន់តែធ្លាប់ឃើញឡានៗនោះមួយបាំងកន្លះ និងមានពណ៌ទាប៊ីកាន ភាគច្រើនចតនៅមុខផ្ទះរបស់បងស្រីខ្លួននៅពេលថ្ងៃ ។

-ឈ្មោះ[redacted]កាន (ត្រូវជាម្តាយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវជាជីដូនរបស់ជនរងគ្រោះ) ឆ្លើយថា៖ ខ្លួនធ្លាប់បានឃើញឈ្មោះ [redacted]រឿន ចេញចូលផ្ទះរបស់កូនស្រីរបស់ខ្លួនឈ្មោះ[redacted]ខុន ជារៀងរាល់ថ្ងៃ ចំណែកឯពេលថ្ងៃយូរៗឃើញម្តង ។ ជាទូទៅខ្លួនបានចេញចូលផ្ទះកូន២ទៅ៣ដងក្នុងមួយថ្ងៃ ប៉ុន្តែនៅពេលដែលឃើញឡានឈ្មោះ [redacted]រឿន ចតនៅនឹងមុខផ្ទះ គឺខ្លួនពុំដែលចូលទេ ។ នៅក្នុងផ្ទះរបស់កូនស្រីខ្លួន ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមានកម្មករចំនួន៥ទៅ៦នាក់ ពេលព្រឹកកម្មករចូលធ្វើការនៅម៉ោង៧ព្រឹក សម្រាកហូបបាយថ្ងៃ១ម៉ោង នៅផ្ទះរបស់កូនស្រីរបស់ខ្លួន និងចេញពីធ្វើការនៅម៉ោង៥ល្ងាច ដោយកម្មករទាំងអស់ធ្វើការរៀងរាល់ថ្ងៃដោយពុំមានថ្ងៃសម្រាកសៅរ៍ ឬអាទិត្យឡើយ ។ នៅពេលដែលឈ្មោះ[redacted]រឿន មកផ្ទះកូនស្រីរបស់ខ្លួន គឺកូនស្រីរបស់ខ្លួនតែងតែនៅផ្ទះជាប្រចាំ ដោយពុំមានថ្ងៃណាមួយកូនស្រីរបស់ខ្លួនពុំនៅផ្ទះឡើយ នៅពេលដែលឈ្មោះ[redacted]រឿន មកលេង ។ ជួនកាលពួកគេទាំងពីរជួបគ្នានៅក្នុងផ្ទះ និងជួនកាលឈ្មោះ[redacted] រឿន បានមកទទួលកូនស្រីរបស់ខ្លួនទៅដើរលេងនៅខាងក្រៅ ។ នៅពេលក្រោយកើតហេតុកូនស្រីរបស់ខ្លួនបានទូរស័ព្ទមកថា ឱ្យទៅមើលផ្ទះចៅស្រីឈ្មោះ[redacted]បញ្ញា ថតរូបភាព និងវីដេអូទុកផង ភ្លាមនោះខ្លួនក៏ទៅផ្ទះចៅស្រីដោយថតវីដេអូ ពេលដែលខ្លួនទៅដល់ពួកគេទាំងអស់គ្នាបានជជែកគ្នាជិតចប់រឿងទៅហើយ ដោយខ្លួនគ្រាន់តែដឹងថាប្រពន្ធរបស់ឈ្មោះ [redacted]រឿន មកសុំសម្របសម្រួលឱ្យដកពាក្យបណ្តឹងដែលកូនស្រីខ្លួនបានប្តឹងទៅលើឈ្មោះ[redacted]រឿន ។

-មេធាវី[redacted]ន ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ មុនប្រឡងថ្នាក់ទី៩ជនរងគ្រោះឈឺរោគគ្រុនពោះវៀន មានអាការៈអស់កម្លាំង ហូបមិនបាន, ដើរមិនរួចរកតែសន្លប់ ពេលនោះម្តាយរបស់ជនរងគ្រោះបាននាំគាត់ទៅពេទ្យដាក់សេរ៉ូម ប៉ុន្តែមិនទាន់ជា ហើយក៏មិនទាន់មានកម្លាំងនៅឡើយទេ ។ លុះដល់ថ្ងៃទី៥ក្នុងខែឆ្នាំងដែល វេលាម៉ោងប្រហែល២ ទៅ៣ ជនជាប់ចោទឈ្មោះ[redacted]រឿន បានមកជួបម្តាយជនរងគ្រោះនៅផ្ទះ ថាមកយកខោអាវគាត់ភ្លេច ម្តាយជនរងគ្រោះឱ្យទៅយកនៅលើ ដោយពេលនោះម្តាយជនរងគ្រោះមិនបាននៅផ្ទះគាត់ចេញទៅក្រៅរកម៉ូយ ជនជាប់ចោទឡើងមកលើ ដោយឆក់ឱកាសពេលឡើងមកលើហើយ ឃើញថាម្តាយមិននៅផ្ទះផង ជនជាប់ចោទគោះទ្វារបន្ទប់ជនរងគ្រោះហើយ គោះទៀត ធ្វើឱ្យជនរងគ្រោះខឹងផងក៏បើកទ្វារដោយសារទ្រាំនឹងសម្លេងគោះទ្វារនោះមិនបាន ពេលនោះស្រាប់ជនជាប់ចោទគាត់រុញទ្វារបន្ទប់ចូលហើយបិទទ្វារចាក់សោរ ហើយស្ទុះមកឱបរឹតជនរងគ្រោះ រួចបានសួរជនរងគ្រោះ ... ស្រលាញ់ពូអត់ ? ហើយពេលនោះជនរងគ្រោះឆ្លើយថា មិនស្រលាញ់ពូឯងទេ ខណៈពេលនោះជនរងគ្រោះព្យាយាមរើបម្រាស់ និងរុញជនជាប់ចោទចេញដើម្បីរត់គេចចេញពីបន្ទប់ តែគាត់គ្មានកម្លាំងដោយសារគាត់កំពុងឈឺ ជនជាប់ចោទបានវាយជនរងគ្រោះ២ដៃ ចំដើមទ្រូងចុងដង្ហើមឈឺខ្លាំង

ស្រែកឱ្យគេជួយមិនរួច ស្មារតីក៏ចុះខ្សោយមិនទាន់ជាពីជម្ងឺទេ ជនរងគ្រោះព្យាយាមសំពះសុំអង្វរកុំឱ្យធ្វើបាបគាត់ គាត់មិនធ្លាប់ធ្វើខុសចំពោះជនជាប់ចោទទេ? នាងនៅក្មេងណាស់ជនជាប់ចោទខ្ទប់មាត់នាងហើយស្រែកថាក្មេងមិនក្មេងអីមិនសំខាន់ទេ ឱ្យតែរញ្ជួចង់បានអីគឺត្រូវតែបានហ្នឹង (នេះជាសម្ដីដាច់ធម៌មេត្តារបស់ជនជាប់ចោទ ) បន្ទាប់ពីនិយាយរួច ជនជាប់ចោទបានចាប់សម្រាតខោអាវជាប់ខ្លួនចេញអស់ហើយ បង្ខំរំលោភរហូតបានសម្រេច ហើយបាននិយាយគំរាមថាបើហ៊ានប្រាប់ម្ដាយ ឬប្រាប់អ្នកដទៃឱ្យដឹងគេនឹងសម្លាប់ចោលទាំងម្ដាយនិងកូន ព្រមទាំងធ្វើឱ្យបាត់បង់កិត្តិយស និងសេចក្ដីថ្លៃថ្នូរក្នុងសង្គមទៀត ។ ជនជាប់ចោទបានគំរាម និងចាប់រំលោភនាងជាបន្តបន្ទាប់រហូតដល់ខែ១០ ឆ្នាំ២០២០ (ចំនួន៧ដង) គំរាមគ្រប់ពេល ពេលមកផ្ទះម្ដងៗសម្លឹងមុខឱ្យសញ្ញា ឃើញមុខគឺខ្លាចដូចខ្លា ដូចត្រូវថ្នាំអញ្ចើង ។ ក្រោយពីកើតហេតុ រួចនាងមានការឈឺចាប់នឹងមានរោគស្ត្រី មានជម្ងឺ, អារម្មណ៍ភ័យខ្លាច, អង្គុយយំ, ចង់នៅតែម្នាក់ឯង និងចង់ធ្វើអត្តឃាតម្ដងៗពេលនឹកឃើញហេតុការណ៍ដែលកើតឡើង ។ ដោយភាពភ័យខ្លាចពីការគំរាមកំហែងពីសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ខ្លាចការរើសអើង, ខ្លាចការស្ដីបន្ទោសពីសាច់ញាតិទើបនាង និងម្ដាយស៊ូទ្រាំលាក់ហេតុការណ៍នេះ និងទុក្ខសោកក្នុងចិត្តរហូតទើបនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ម្ដាយមីង និងម៉ាក់យាយគាត់ឆ្ងល់ដោយនាងមានភាពស្ងៀមស្ងាត់មួយរយៈ មិននិយាយស្ដីជាមួយបងប្អូន ទើបនាង និងម្ដាយបាននិយាយរឿងនេះប្រាប់ម្ដាយមីងឈ្មោះ អ៊ាប ឌីណា ។ ស្អែកឡើង បាននាំមកអង្គការសម្ព័ន្ធចាប់ដៃ និងក្រសួងកិច្ចការនារី ដើម្បីជួយស្វែងរកយុត្តិធម៌ជូននាង និងក្រុមគ្រួសារ ។ តាមរបាយការណ៍លេខ ០២៦ / ២២ រ.ប.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្សខាងកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted]រឿន ពិតជាបានធ្វើសកម្មភាព និងមានពិរុទ្ធភាពដូចក្នុងករណីចោទប្រកាន់ពិតប្រាកដមែន ។ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ខុន និងចម្លើយរបស់ជនរងគ្រោះ [redacted]បញ្ញា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]រឿន តាមឯកសារពិនិត្យផ្លូវភេទលេខ ២៧ / ២២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ យល់ឃើញថាជនជាប់ចោទគាត់មានកាយសម្បទាគ្រប់គ្រាន់ បានរៀនសូត្រចេះដឹង មានការងារធ្វើជាយោធា ជាមនុស្សសាហាវឃោរឃៅ អមនុស្ស មិនមានការទទួលខុសត្រូវ មានចេតនាទុច្ចរិត និយាយមិនពិត ព្យាយាមលាក់ការពិត ព្យាយាមបដិសេធពីការពិត តែការពិតនៅតែជាការពិត ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]រឿន បានធ្វើសកម្មភាពចាប់រំលោភលើកុមារីរងគ្រោះច្រើនលើកច្រើនសារដល់ទៅ៧ដង និងមានការធ្វើទារុណកម្ម បង្ខិតបង្ខំ គំរាមកំហែងថានឹងសម្លាប់ បើហ៊ាននិយាយរឿងរំលោភប្រាប់ម្ដាយ និងប្រាប់អ្នកដទៃ ។ អំពើរបស់ជនជាប់ចោទ បង្កឱ្យមានការប៉ះពាល់ដល់សុខភាពរាងកាយរបស់ជនរងគ្រោះ១បច្ចុប្បន្នមានជម្ងឺរោគស្ត្រីប្រចាំកាយ ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ ជាពិសេសប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ហើយអំពើរបស់ជនជាប់ចោទត្រូវបានច្បាប់ហាមឃាត់ និងបំពានបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ដែលត្រូវបានច្បាប់កំណត់ថាជាបទល្មើស **រំលោភសេពសន្ថវៈ និងរំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** តែនៅក្នុងដីកាចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ចោទតែមាត្រា ២៣៩ បទរំលោភសេពសន្ថវៈ តែយោងតាមអង្គហេតុ និងព្យសនកម្មកើតមានមកលើជនរងគ្រោះវាធ្ងន់ធ្ងរណាស់ រំលោភហើយធ្វើទារុណកម្ម គំរាមថាសំលាប់បើនាង និងម្ដាយហ៊ានប្ដឹង ឬ

និយាយប្រាប់គេឲ្យដឹងរឿងនោះ អង្គហេតុនេះវាជាអំពើរំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោស ហេតុនេះ ប្ដឹងសុំដល់តំណាងអយ្យការ និងប្រធានរួមទាំងក្រុមប្រឹក្សា សុំកែប្រែបទចោទតាមមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។ ចំណុចសំខាន់មួយដែលដើមបណ្ដឹង និងជនរងគ្រោះមានការព្រួយបារម្ភដោយ គាត់បានទទួលពត៌មាននៅជិតសវនាការនេះ ដោយជនជាប់ចោទបានថតរូបបង្ហោះឲ្យឃើញ និងបានដឹងកាន់តែច្បាស់ ពេលដែលខ្ញុំបានសំណុំរឿងមកសិក្សា នៅពេលបញ្ជូនរឿងមកជំនុំជម្រះ ទោះបីដឹងថាលោកស្រីចៅក្រម [redacted] រួច ដែលជាចៅក្រមស៊ើបសួរគាត់បានចេញដីកាដោះលែងឲ្យជនជាប់ចោទនៅក្រៅឃុំ ដោយគាត់មិនបានជូនដំណឹងដល់ខ្ញុំជាមេធាវី និងដើមបណ្ដឹងឡើយ ។ ខ្ញុំ ដើមបណ្ដឹង និងជនរងគ្រោះមានការបារម្ភពីសន្តិសុខ សុវត្ថិភាព របស់ពួកគាត់ខ្លាំងណាស់ ពេលដែលបានដឹងថានឹងឃើញជនជាប់ចោទចេញក្រៅឃុំដោយជនជាប់ចោទកន្លងមកបានប្រើហិង្សាគំរាមកំហែងថានឹងសម្លាប់ បើដើមបណ្ដឹង ហ៊ានបែកពីគាត់ និងបើដើមបណ្ដឹង និងជនរងគ្រោះហ៊ានយករឿងរំលោភនោះទៅប្រាប់គេ ឬយកទៅប្ដឹង គាត់នឹងសម្លាប់ចោលទាំង៣នាក់ម្ដាយកូន ។ ដើមបណ្ដឹង និងជនរងគ្រោះខ្លាចទើបរឿងនោះលាក់ទុកការឈឺចាប់នេះរហូតមិនហ៊ានប្ដឹងព្រោះជនជាប់ចោទ គាត់ជាយោធា មានអំណាច និងមានគូកនច្រើនណាស់ ចំណុចនេះហើយដែលដើមបណ្ដឹង និងជនរងគ្រោះ មានការបារម្ភ ចំណុចនេះសុំតំណាងអយ្យការ និងលោកប្រធាន រួមទាំងលោកចៅក្រមប្រឹក្សាមេត្តាពិចារណា និងស្នើសុំដោះស្រាយ ។ យោងតាមអង្គហេតុ និងភស្តុតាងនានាបានបង្ហាញឲ្យឃើញថាជនត្រូវចោទពិតជាបានធ្វើសកម្មភាពដូចតាមការលើកឡើងពិតប្រាកដមែន ហើយមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទរំលោភសេពសន្ថវៈ និងរំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ តាមមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។ អង្គច្បាប់យោងតាមមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។ មាត្រា ២៣៩ បទរំលោភសេពសន្ថវៈ គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើអំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។ មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ បទរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ ១-បុគ្គលដែលមានភាពទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។ ២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្ដែង ឬកាលបើជនល្មើសបានដឹង ។ ៣-បុគ្គលដែលមានភាពទន់ខ្សោយពិសេស ដោយមូលហេតុនៃជម្ងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្ដែង ឬកាលបើជនល្មើសបានដឹង ។ ក្នុងរឿងនេះជនជាប់ចោទបានដឹងថាជនរងគ្រោះមានអាយុតិចជាង១៥ឆ្នាំ និងមានជម្ងឺដែរ ដោយជនរងគ្រោះបានអង្វរសំពះហើយប្រាប់ជនជាប់ចោទកុំធ្វើបាប តែជនជាប់ចោទមិនលើកលែងទេ គាត់នៅតែអនុវត្តគម្រោង ផែនការគិតទុកជាមុនរបស់គាត់ចាប់រំលោភជនរងគ្រោះឈ្មោះ [redacted] ដែលមានអាយុទើបតែ១៥ឆ្នាំ រហូតបានសម្រេចដល់ទៅ៧ដង នៅក្នុងខណៈពេលដែលជនរងគ្រោះគ្មានកម្លាំងតបត និងគំរាមកំហែងថានឹងសម្លាប់ជនរងគ្រោះ ប្អូន និងម្ដាយ ហើយអំពើរបស់ជនជាប់ចោទបង្កឲ្យមានព្យសនកម្ម ចេញពីអំពើដោយផ្ទាល់របស់ជនត្រូវចោទមកលើជនរងគ្រោះ គឺជាចេតនាទុច្ចរិតក្នុងការបំពារបំពានដល់រូបរាងកាយកិត្តិយស និងសេចក្ដីថ្លៃថ្នូរបស់អ្នកដទៃ និងសណ្ដាប់

ធ្លាប់សាធារណៈរបៀបរៀបរយសីលធម៌ល្អក្នុងសង្គម ។ ហេតុដូច្នេះក្នុងនាមនាងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះទាំងម្តាយទាំងកូន សំណូមពរដល់ថៅក្រមប្រឹក្សា ជាពិសេសលោកតំណាងអយ្យការមេត្តាដាក់ទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ឱ្យបានតឹងរឹងដើម្បីជាការព្រមានដល់ជនក្រោយៗ កុំឱ្យប្រព្រឹត្តអំពើនេះមកលើជនរងគ្រោះជាមនុស្សទន់ខ្សោយមានជម្ងឺ ជាពិសេសជនរងគ្រោះជាអនីតិជនទៀត ។ សុំឱ្យតុលាការបង្គាប់លិខិតឆ្លងដែនជនជាប់ចោទ និងសុំចេញដីកាចាប់ខ្លួនជនត្រូវចោទក្រោយពេលប្រកាសថាមានទោស ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនរងគ្រោះ និងព្រមទាំងភស្តុតាងផ្សេងៗដែលមានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ[redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ នៅចំណុច ផ្ទះលេខ[redacted]០ [redacted] រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវី[redacted]ហ៊ាង ការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ឈ្មោះ[redacted]ខុន បានដាក់ពាក្យបណ្តឹងប្តឹងចោទលើឈ្មោះ[redacted]រឿន ពីបទ រំលោភសេពសន្ថវៈ ថាបានប្រព្រឹត្តកាលពីអំឡុងខែសីហា ឆ្នាំ២០២០ ដោយបានបញ្ជាក់ថាឈ្មោះ[redacted]រឿន បានរំលោភសេពសន្ថវៈទៅលើកូនស្រីរបស់ឈ្មោះ[redacted]បញ្ញា ភេទស្រី ។ មុនពេលកើតហេតុឈ្មោះ[redacted]រឿន និងឈ្មោះ [redacted]ខុន ភេទស្រី បានមានទំនាក់ទំនង និងរួមរស់ជាប្តីប្រពន្ធអនីតិសង្វាសជាមួយគ្នា ។ ក្នុងអំឡុងពេលរួមរស់ជាប្តីប្រពន្ធអនីតិសង្វាសនោះឈ្មោះ [redacted]ខុន ថាឈ្មោះ[redacted]រឿន បានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ បានសម្រេចលើកូនស្រីឈ្មោះ [redacted]បញ្ញា ភេទស្រី ។ ក្រោយមកនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២២ ទើបឈ្មោះ[redacted]ខុន ដាក់ពាក្យស្នើសុំកិច្ចអន្តរាគមន៍ចូលមកក្រសួងកិច្ចការនារី ។ ត្រង់ចំណុចនេះ ខ្ញុំបាទសូមបញ្ជាក់ថាបើពិនិត្យទៅលើចម្លើយ និងឯកសារពាក់ព័ន្ធផ្សេងៗដែលដើមបណ្តឹងបានដាក់បញ្ចូលនៅក្នុងសំណុំរឿងឃើញថា ភស្តុតាងទាំងអស់គឺមិនមានភាពស៊ីសង្វាក់គ្នាទាល់តែសោះ ។ ដើមបណ្តឹង និងកូនស្រីដាក់ពាក្យបណ្តឹងនិងរៀបរាប់ដោយឯកឯងដោយមិនមានភាពច្បាស់លាស់នោះទេ ជាពិសេសការលើកឡើងអំពីថេរៈវេលាដែលចោទថាឈ្មោះ[redacted]រឿន បានធ្វើសកម្មភាពរំលោភសេពសន្ថវៈទៅលើឈ្មោះ[redacted]បញ្ញា ។ ម្តាយអះអាងថាថ្ងៃផ្សេង ហើយកូនថាថ្ងៃផ្សេង ម្តងថាពេលរំលោភម្តាយនៅផ្ទះ ម្តងថាមិនមានមនុស្សនៅផ្ទះ ។ ម្តងថាខ្លាចការគំរាមមិនហ៊ានប្រាប់ម្តាយ ម្តងថាពេលកើតហេតុភ្លាមចុះមកប្រាប់ម្តាយភ្លាម តែថាខ្លួនខ្លាចការគំរាមទើបមិនហ៊ានប្តឹង ម្តាយអះអាងថាដឹងភ្លាមទូរស័ព្ទទៅរកឈ្មោះ[redacted]រឿន ភ្លាម កូនស្រីថារំលោភដល់ទៅប្រាំពីរលើកទើបហ៊ានប្រាប់ម្តាយ ។ អះអាងថាមានការចាប់រំលោភដោយបង្ខំ និងហិង្សា ប៉ុន្តែឯកសាររូបភាពជាភស្តុតាង៖ សំលៀកបំពាក់ថ្ងៃរំលោភដែលមើលឃើញថាឈុតដេក គឺមិនមានការដាច់រហែកអ្វីនោះទេ មានរូបភាពស្នើតែគ្រប់ជ្រុងនៃផ្ទះដែលថាជាកន្លែងកើតហេតុ ដែលសន្និដ្ឋានបានថាជាភស្តុតាងដែលបង្កើតឡើងដើម្បីទម្លាក់កំហុសយ៉ាងប្រាកដ ដោយហេតុថាភស្តុតាងដែលសំខាន់ និងស៊ីសង្វាក់ពាក់ព័ន្ធនឹងការកើតហេតុ

ជាក់ស្តែងគឺមិនមានដូចជា ថតស្លាកស្នាមដែលអះអាងអំពីការបង្ខំ និងហិង្សាបានទៅមន្ទីរពេទ្យប៉ុន្តែមិនមានលិខិតបញ្ជាក់អំពីស្លាកស្នាម និងរបួសអំពីអំពើរំលោភ ត្រង់ចំណុចនេះសូមបញ្ជាក់ថាហេតុអ្វីក៏មិនមានភស្តុតាងទាំងនោះ មូលហេតុគឺមិនមានការរំលោភសេពសន្ថវៈអ្វីនោះទេ ដូច្នេះគឺមិនមានភស្តុតាងបែបនោះឡើយ ហើយក៏មិនអាចបង្កើតមកបានដែរ ។ នៅក្នុងសំណុំរឿងនេះពុំឃើញមានភស្តុតាង (ឯកសារកោសលវិច្ច័យ) ឬសាក្សីណាមួយបង្ហាញ និងបញ្ជាក់ថាកូនក្តីរបស់ខ្ញុំបាទបានប្រព្រឹត្តករណី *រំលោភសេពសន្ថវៈ* នោះទេ ។ មានតែភស្តុតាងជាលិខិតចេញពីមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ដែលទើបតែពិនិត្យនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២ ទៅវិញ ដូចនេះគឺមិនមានភស្តុតាង និងសាក្សី ឯណាដើម្បីចោទប្រកាន់កូនក្តីរបស់ខ្ញុំបាទនោះទេ ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា *(ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវ តាមបញ្ញត្តិច្បាប់ និងវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ)* ។ មាត្រា ២៥៥,៣៥១ (អវត្តមានជនជាប់ចោទ) វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧ ។ ការចោទប្រកាន់ពីបទ *រំលោភសេពសន្ថវៈ* ពីសំណាក់លោកតំណាងរយ្យការ មកលើកូនក្តីរបស់ខ្ញុំបាទ តាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ គឺជាការមិនត្រឹមត្រូវទេ ព្រោះពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលអាចធ្វើការចោទប្រកាន់បាន ហើយម្យ៉ាងវិញទៀតក្នុងករណីនេះ គឺពុំមានភស្តុតាង (ឯកសារកោសលវិច័យបញ្ជាក់ ពិតជាមានការរំលោភនោះទេនៅថ្ងៃកើតហេតុ) ។ ជាគោលការណ៍ច្បាប់បើមានការរំលោភមែនគឺសកម្មភាពចាប់រំលោភតែម្តងចប់ តែនេះរំលោភដល់ទៅចំនួន៧លើក តើនេះជាអំពើចាប់រំលោភដែរទេ ? ដូចនេះសរុបសេចក្តីមកកូនក្តីរបស់ខ្ញុំបាទពេលនេះ គឺកំពុងស្ថិតនៅក្នុងវិមតិសង្ស័យនៅឡើយទេ ត្រូវបានការពារដោយច្បាប់ តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សំណូមពរសុំអង្គសវនាការទាំងមូល មេត្តាពិនិត្យលើអង្គហេតុ និងអង្គច្បាប់ និងសុំរកយុត្តិធម៌ឱ្យកូនក្តីរបស់ខ្ញុំបាទងសំណុំរឿងនេះ ព្រោះកូនក្តីរបស់ខ្ញុំបាទ គឺស្ថិតនៅក្នុងវិមតិសង្ស័យតែប៉ុណ្ណោះ និងសុំឱ្យកូនក្តីរបស់ខ្ញុំបាទរួចផុតពីបទចោទប្រកាន់ចាប់ពីពេលនេះតទៅ ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ សុំឱ្យតុលាការជួយរកយុត្តិធម៌ និងសម្រេចឱ្យរួចផុតបទចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

-តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ចែងថា បទរំលោភសេពសន្ថវៈ គ្រប់អំពើបញ្ចូលអវយវៈភេទ តាមបែបណាក៏ដោយ ឬបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីជាភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

-តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ចែងថា ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ រំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជម្ងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

-យល់ឃើញពីហេតុការណ៍ប្រព្រឹត្តនៃបទល្មើស៖ កាលពីថ្ងៃមិនចាំ ក្នុងអំឡុងខែសីហា ឆ្នាំ២០២០ នៅចំណុច ផ្ទះលេខ៥៩E0 ផ្លូវលេខ[redacted] រាជធានីភ្នំពេញ ពិតជាកើតមាននូវករណី រំលោភសេពសន្ថវៈ ដែលបង្កដោយឈ្មោះ [redacted]ឡៀង ភេទប្រុស អាយុ៤៣ឆ្នាំ ពិតជាបានធ្វើសកម្មភាពចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ [redacted]បញ្ញា ភេទស្រី អាយុ១៥ ឆ្នាំ ហើយក៏ត្រូវជនរងគ្រោះប្រាប់ម្តាយឈ្មោះ [redacted]ខុន ជាម្តាយរបស់ជនរងគ្រោះបានដាក់ពាក្យបណ្តឹងប្តឹងទៅសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមច្បាប់ ។

-តាមរបាយការណ៍សរុបលេខ៖ ០៦៦/២០២២ រ.ប.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេសស្នងការដ្ឋានស្រាវជ្រាវ និងបង្ក្រាបបទល្មើសការិយាល័យប្រឆាំងការជួញដូរមនុស្ស បានសន្និដ្ឋានថាជនសង្ស័យឈ្មោះ [redacted]រឿន ភេទប្រុស អាយុ៤១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ នៅចំណុច ផ្ទះលេខ[redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ ប្រាកដមែន ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]រឿន នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចំពោះមុខតំណាងអយ្យការ ចំពោះមុខចៅក្រមស៊ើបសួរ និងពេលសវនាការ បានឆ្លើយបដិសេធថា ខ្លួនពុំប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះឈ្មោះ [redacted]បញ្ញា នោះទេ ។ ការបដិសេធរបស់ជនជាប់ចោទរូបនេះគ្រាន់តែលេសក្នុងការដោះសារអំពីអំពើរបស់ខ្លួនតែប៉ុណ្ណោះ ដោយពុំមានភស្តុតាង សាក្សីណាច្បាស់លាស់ក្នុងការដោះបន្ទុក ដើម្បីឱ្យក្រុមប្រឹក្សាជំនុំជម្រះយកមកពិចារណា និងសម្រេចតាមបានឡើយ ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ខុន បានឆ្លើយថា ឈ្មោះ[redacted]រឿន ពិតជាប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ មកលើកូនស្រីរបស់ខ្លួនឈ្មោះ[redacted]បញ្ញា ភេទស្រី អាយុ១៦ឆ្នាំ ពិតប្រាកដមែន ហើយក៏ត្រូវដើមបណ្តឹងរដ្ឋប្បវេណី បានមកធ្វើការដាក់ពាក្យបណ្តឹងលើជនជាប់ចោទតាមច្បាប់ពិតប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សី របាយការណ៍របស់នគរបាលយុត្តិធម៌ និងព្រមទាំងភស្តុតាងផ្សេងទៀតមានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ[redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ (បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ) នៅចំណុច ផ្ទះលេខ[redacted] រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានដោយរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលើជនជាប់ចោទទុកជាបានការដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ទុកនៅដដែល ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរក្សាការចោទប្រកាន់លើជនជាប់ចោទពុំត្រឹមត្រូវបានរង្គហេតុ ធៀបនឹងអង្គច្បាប់ឡើយ ដោយមូលហេតុថាជនជាប់ចោទបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះឈ្មោះ[redacted]បញ្ញា ភេទស្រី កើតថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ដែលជនរងគ្រោះគឺជាអនីតិជន ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះគប្បីពិចារណា និងសម្រេចកែប្រែបទចោទលើជនជាប់ចោទឈ្មោះ[redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ មកជាបទ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ (បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ) តាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវី[redacted] គីមហ៊ាង ដែលមានជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យរួចផុតពីបទចោទនោះ គឺពុំមានមូលហេតុសមរម្យ និងភស្តុតាងពិតប្រាកដឯណា អាចឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមបានឡើយ ។

-តាមឯកសារពិនិត្យការរំលោភផ្លូវភេទ លេខ២៧/២២ របស់ក្រសួងសុខាភិបាលអង្គភាពមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានពិនិត្យ និងធ្វើកោសលវិច័យទៅលើជនរងគ្រោះឈ្មោះ[redacted]បញ្ញា ហៅ លីហ័រ ភេទស្រី កើតថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥ បានធ្វើសេចក្តីសន្និដ្ឋានថា និងអនុសាសន៍ថា៖ តាមការពិនិត្យសភាពរូបកាយទូទៅបង្ហាញឲ្យឃើញមានសភាពធម្មតា តាមការពិនិត្យប្រដាប់ភេទផ្នែកខាងក្រៅបង្ហាញឲ្យឃើញថា សន្ទះព្រហ្មចារីមានស្លាមរហែកចាស់ត្រង់ចំណុចម៉ោង៦ ។ សន្និដ្ឋាន តាមការពិនិត្យទៅលើជនរងគ្រោះបង្ហាញឲ្យឃើញថា៖ សភាពរូបកាយទូទៅធម្មតា សភាពប្រដាប់ភេទផ្នែកខាងក្រៅមិនធម្មតា (ស្លាមរហែកចាស់នៃសន្ទះព្រហ្មចារី) ចំណុចនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី និងការពិនិត្យភស្តុតាងផ្សេងៗតុលាការយល់ឃើញថា៖

ក/ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]រឿន គឺជាបទល្មើស រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដែលមានចែងក្នុងបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

ខ/ សកម្មភាពដែលស្តែងឡើងរបស់ជនជាប់ចោទឈ្មោះ [redacted] [redacted]រឿន បានប្រើប្រាស់អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឆ្មក់ឱកាសក្នុងការរំលោភសេពសន្ថវៈ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះជាបទល្មើស រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

គ/ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] [redacted]រឿន មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើសអំពើ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដោយបានប្រើប្រាស់អំពើហិង្សា និងបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុនៃបុគ្គលនោះ ។

-យល់ឃើញពីសមត្ថភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ផ្អែកតាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទរូបនេះជានីតិជនមានស្មារតីគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយបញ្ជាក់មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះជននេះត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] [redacted]ន បានប្តឹងទាមទារឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ តាមផ្លូវច្បាប់ និងទាមទារសំណងជម្ងឺចិត្តសរុបចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ក្រុមប្រឹក្សាជំនុំជម្រះនឹងសម្រេចតាមព្យសនកម្មជាក់ស្តែង ។

-តាមការពិនិត្យទៅលើរង្គហេតុ និងរង្គច្បាប់ យល់ឃើញថាឈ្មោះ [redacted] [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ បានធ្វើសកម្មភាព រំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះឈ្មោះ [redacted]បញ្ញា ភេទស្រី កើតថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥ ជាអនីតិជន ដែលមានច្បាប់បញ្ញត្តិតាមមាត្រា ២៤១ ចែងថា ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។ ហេតុដូច្នេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចកែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ មកបទ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ វិញ ។

-ជនជាប់ចោទឈ្មោះ [redacted] [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ មុខរបរមន្ត្រីយោធា មានទីលំនៅច្បាស់លាស់ មានមេធាវីការពារសិទ្ធិស្របច្បាប់ និងតែងតែចូលខ្លួនមកកាន់តុលាការតាមការកោះហៅ នៅពេលដែលចៅក្រមស៊ើបសួរអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ចំណុចនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាផ្តន្ទាទោសតាមច្បាប់ ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុច ផ្ទះលេខ[redacted] [redacted] រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១/. កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ពីបទ៖ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ មកបទ៖ **រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុច ផ្ទះលេខ[redacted] ផ្លូ[redacted] [redacted] [redacted]រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ ។

២/. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]រឿន ភេទប្រុស អាយុ៤៣ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៧ (ប្រាំពីរ) ឆ្នាំ ពីបទ៖ **រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ[redacted] [redacted] [redacted] រាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

៣/. បង្គាប់ឱ្យឈ្មោះ [redacted] [redacted]រឿន សងសំណងជម្ងឺចិត្តទឹកប្រាក់សរុបចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ឌុន ការទាមទារលើសពីនេះតុលាការច្រានចោល ។

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ និងនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]រឿន និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ឌុន ប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]